ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៤៨/១១-ដាយ យ៉ាំង
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ដាយ យ៉ាំង (ខេមបូឌា)**
អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៨៣០ ៩០១ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

១- លោក ព្រាប ឡេន ប្រធានរដ្ឋបាល
២- លោក ជូ ចាន់ស័ក ទីប្រឹក្សាក្រុមហ៊ុន

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖- **សហព័ន្ធសហជីពការពារកម្មករកម្ពុជា**
- **សហជីពការពារកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ដាយ យ៉ាំង**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៩២ ៨០០ ៩៦៣ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត:

១- លោក ឈិន សូនី អនុប្រធានសហព័ន្ធសហជីពការពារកម្មករកម្ពុជា

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

| | |
|---|---|
| ២- លោក អ៊ិន នេត | ប្រធាន CLOWBUF |
| ៣- លោក ខៀវ ឌីណា | មន្ត្រី CLOWBUF |
| ៤- លោក ញ៉ៀត វណ្ណី | ប្រធានសហជីពការងារកម្មករកម្ពុជាប្រចាំរោងចក្រដាយយ៉ាំង |
| ៥- លោក វ៉ូ សុផាន់ណារ៉ា | អនុប្រធានសហជីព |
| ៦- លោក ស៊ូ ហេង | មន្ត្រីសហជីព |
| ៧- លោក យ៉ុន សាវុធ | មន្ត្រីសហជីព |
| ៨- លោក ហ៊ិន គីមឈាង | មន្ត្រីសហជីព |
| ៩- កញ្ញា អោក បូរី | មន្ត្រីសហជីព |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនគោរពនូវសេចក្តីជូនដំណឹងរបស់ខ្លួន ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ត្រង់ចំណុចវិវាទទី ១, ២ និងទី៣ ។

២- សុំឱ្យក្រុមហ៊ុនគោរពនូវសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១។

៣- សុំឱ្យក្រុមហ៊ុនរៀបចំទឹកក្នុងបង្គន់ឱ្យបានគ្រប់គ្រាន់ ។

៤- ក្រុមហ៊ុនមិនត្រូវបង្ខិតបង្ខំកម្មករនិយោជិតដែលដេរមិនបានគ្រប់ចំនួន ។

៥- ក្រុមហ៊ុនមិនត្រូវធ្វើការគំរាមកំហែងកម្មករនិយោជិតដែលចូលរួមធ្វើកូដកម្មរយៈពេលកន្លងមក ។

៦- ក្រុមហ៊ុនមិនត្រូវដាក់ធុងបាស់ ឬកាមេរ៉ាតាមផ្លូវចូលបន្ទប់ទឹកឡើយ ។

៧- រាល់ពេលដែលមានបុណ្យផ្សេងៗ ក្រុមហ៊ុនត្រូវតែពិភាក្សាជាមួយសហជីពដែលមានភាពតំណាងឱ្យបានដឹងផងពីរថ្ងៃមុន ។

៨- សុំឱ្យក្រុមហ៊ុនរៀបចំបន្ទប់ប្រជុំសម្រាប់សហជីព ដែលមានភាពជាតំណាង ។

៩- ក្រុមហ៊ុនត្រូវតែធ្វើការព្រមានប្រធានចិន ដែលប្រើពាក្យសំដីមិនសមរម្យមកលើកម្មករនិយោជិត ។

១០- ក្រុមហ៊ុនមិនត្រូវធ្វើការគៀបសង្កត់មកលើកម្មករម្តងម្កាលឡើយ ។

១១- នៅពេលកម្មការិនីធ្វើការបាន ៩ ខែ ហើយដាក់ពាក្យឈប់សម្រាកលំហែមាតុភាព សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលជូន ។

១២- ក្រុមហ៊ុនមិនត្រូវធ្វើការផ្លាស់ប្តូរកម្មករនិយោជិតពីកន្លែងមួយទៅកន្លែងមួយឡើយ ។

១៣- ក្រុមហ៊ុនបានសន្យាថា នឹងរក្សាប្រាក់ឈ្នួលដល់កម្មករនិយោជិត ដែលចូលរួមធ្វើកូដកម្មកន្លងមក ប៉ុន្តែពុំអនុវត្ត ។

ARBITRATION COUNCIL

១៤- សុំឱ្យបុគ្គលិកការិយាល័យធ្វើការឱ្យបានច្បាស់លាស់ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១២៤៦ កប/អក/វក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧
(ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (វេលាម៉ោង ២ រសៀល ) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពការងារកម្មករកម្ពុជា ស្តីពីការកែលំអរលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារជាបន្តបន្ទាប់ និងបានផ្សះផ្សាវិវាទការងារ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ ចំនួន១៤ចំណុច ប៉ុន្តែមិនបានទទួលលទ្ធផលសះជានឹងគ្នាលើការទាមទារទាំង១៤ចំណុចនេះទេ ។

ចំណុចមិនសះជាចំនួន១៤ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១២៤៦ កប/អក/វក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីទាំងពីរមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាក្នុងសំណុំរឿងនេះ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាននៅសវនាការ តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្នុងសវនាការ ភាគីកម្មករនិយោជិតមិនមានលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពទេ ហើយសន្យាថា នឹងផ្តល់លិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ប៉ុន្តែភាគីកម្មករនិយោជិតមិនបានផ្តល់ឯកសារតាមការសន្យានោះទេ។ ចំពោះភាគីនិយោជកក៏ចង់

ឱ្យសហជីពបង្ហាញឯកសារលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពនោះដែរ។ នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពន្យល់ប្រាប់ភាគីថា ប្រសិនបើគ្មានលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពទេ។ ភាគីកម្មករនិយោជិតមិនមានសិទ្ធិជាភាគីវិវាទនៅក្នុងសំណុំរឿងនេះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយសំណុំរឿងនេះ ដូចខាងក្រោម៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ដាយ យ៉ាំង ជូនលោក ព្រាប ឡេន និងលោក ជូ ចាន់ស័ក ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១១ ។

២- លក្ខន្តិកៈក្រុមហ៊ុន ដាយ យ៉ាំង ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៣ ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ដាយ យ៉ាំង ចុះថ្ងៃ១៧ ខែមីនា ឆ្នាំ២០០៤ ។

៤- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ដាយ យ៉ាំង ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០១១ ។

៥- ដីការសំរេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ លេខ ១៧ "រឆ " ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០១១ ។

៦- លិខិតរបស់នាយក្រុមហ៊ុន ដាយ យ៉ាំង គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការស្នើសុំពិចារណាលើករណី ដែលពាក់ព័ន្ធសវនាការដោយសមាសភាពតំណាងកម្មករជាប់ពាក់ព័ន្ធនឹងបណ្តឹងនៅសាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៧- ដីកាកោះរបស់សាលាដំបូងរាជធានីភ្នំពេញសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៧៨ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១១ ។

៨- ដីកាកោះរបស់សាលាដំបូងរាជធានីភ្នំពេញសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៧៨ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១ អញ្ជើញឈ្មោះ មាស សុខឿន ។

៩- ដីកាកោះរបស់សាលាដំបូងរាជធានីភ្នំពេញសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៧៨ ចុះថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០១១ អញ្ជើញឈ្មោះ ញ៉ែត វណ្ណី ។

១០- ដីកាកោះរបស់សាលាដំបូងរាជធានីភ្នំពេញសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៧៨ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១១ អញ្ជើញឈ្មោះ ថន សាបាន ។

១១- ដីកាកោះរបស់សាលាដំបូងរាជធានីភ្នំពេញសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៧៨ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ អញ្ជើញឈ្មោះ រ៉ូ សុផាន់ណារ៉ា ។

THE ARBITRATION COUNCIL

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតរបស់សហព័ន្ធសហជីពការងារកម្មករកម្ពុជា លេខ ៦៧/២០១១ សសកកក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ជូនចំពោះលោកប្រធាននាយកដ្ឋានវិវាទការងារ ក្នុងការជួយដោះស្រាយវិវាទនៅរោងចក្រ ដាយ យ៉ាំង ។

២- សេចក្តីជូនដំណឹង (ទាក់ទងនឹងការផ្តល់ប្រាក់ឧបត្ថម្ភមួយចំនួន) ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ។

៣- លិខិតរបស់តំណាងកម្មករ និងសហជីពការងារកម្មករកម្ពុជានៃរោងចក្រ ដាយ យ៉ាំង ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ជូនចំពោះលោកប្រធាននាយកដ្ឋានវិវាទការងារ ក្នុងការជួយដោះស្រាយវិវាទនៅរោងចក្រ ដាយ យ៉ាំង ។

៤- សេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ៨៨/១១ និង ៨៩/១១-ដាយ យ៉ាំង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ដាយ យ៉ាំង លេខ ១២៤៦ កប/អក/វក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ដាយយ៉ាំង ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៨៧០ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៨៧១ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ។

**អង្គហេតុ**

- គ្មានការរកឃើញអង្គហេតុក្នុងករណីនេះទេ ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើភាគីកម្មករនិយោជិត ដែលមានវត្តមានក្នុងសវនាការ ពិតជាថ្នាក់ដឹកនាំសហជីពការងារកម្មករកម្ពុជា ដែលមានការទទួលស្គាល់តាមផ្លូវច្បាប់ ក្នុងការធ្វើជាតំណាងដើមបណ្តឹងនៅក្នុងសំណុំរឿងនេះដែរ ឬទេ?

ផ្អែកតាមសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ភាគីដែលធ្វើការអះអាង ឬចោទប្រកាន់ គឺមានបន្ទុកផ្តល់ភស្តុតាង ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ៧៩/០៥-អេវើរប្រ៊ីត, លេខ ១ ០៧/០៨-ជីឌីអ៊ីមុ ហោត*

*ផលចំណុចវិវាទទី១ និងទី២, លេខ ១០៨/០៨-ហ៊ូហ្គោ ហេតុផលចំណុចវិវាទទី៤, លេខ ១៦៣/០៩-តាកហ្វាត ហេតុផលចំណុចវិវាទទី២, លេខ ១៦៨/០៩-ទីកថ្លា ផ្លាហ្សា ហេតុផលចំណុចវិវាទទី២ និងលេខ ១១៥/១០-ជី-ហ្វម៉ូស ហេតុផលចំណុចវិវាទទី១៨)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗផងដែរ ។ នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត ដែលមានវត្តមានក្នុងសវនាការមានបន្ទុកក្នុងការបង្ហាញថា ពួកគាត់ពិតជាថ្នាក់ដឹកនាំសហជីពការងារកម្មករកម្ពុជា ដែលទទួលបានការទទួលស្គាល់តាមផ្លូវច្បាប់ ។ យ៉ាងណាមិញ មកដល់កាលបរិច្ឆេទដាក់ភស្តុតាង នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ភាគីកម្មករនិយោជិតក្នុងសវនាការ ដែលអះអាងថា ពួកគាត់ជាថ្នាក់ដឹកនាំសហជីពក្នុងសំណុំរឿងនេះ មិនបានដាក់ជូននូវភស្តុតាងណាមួយ ជាពិសេស គឺលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពអណត្តិថ្មី ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។ ហេតុនេះ ភាគីកម្មកនិយោជិតដែលអះអាងថា ខ្លួនជាថ្នាក់ដឹកនាំសហជីពគឺមិនអាចយកជាបានការឡើយ ។ ដូច្នេះ ភាគីកម្មកនិយោជិតនោះមិនអាចតំណាងសមាជិករបស់ខ្លួនក្នុងសំណុំរឿងនេះបានទេ ។

លើសពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដោយសារមិនមានតំណាងដើមបណ្តឹងស្របច្បាប់ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានថា គ្មានការរកឃើញនូវអង្គហេតុទេ ។

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងនេះ ដោយមូលហេតុ គ្មានដើមបណ្តឹងក្នុងការទាមទារ ។

ដោយសំអាងលើអង្គហេតុ ភស្តុតាង អង្គច្បាប់ និង ហេតុផលដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចទៅ ៖

**សម្រេច និង បង្គាប់**

- បិទសំណុំរឿងលេខ ១៤៨/១១-ដាយ យ៉ាំង ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុន្ធី**

ហត្ថលេខា: -------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា: -------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា: -------------------------------